
© Pha Sina / WWF-Cambodia

# អំពីអង្គការ WWF-កម្ពុជា

## បេសកកម្ម និងសារដារបស់អង្គការ

បេសកកម្មរបស់អង្គការ WWF-កម្ពុជា គឺជានាឱ្យមានការចូលរួម និងការគាំទ្រពីមនុស្សគ្រប់រូប ក្នុងការអភិរក្សជីវៈចម្រុះដ៏សម្បូរបែបនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ អង្គការ WWF-កម្ពុជា ក៏លើកកម្ពស់ឱកាសថ្មីៗ ដែលផ្តល់ផលប្រយោជន៍ដល់ប្រជាពលរដ្ឋ និងជួយលើកកម្ពស់ជីវភាពរស់នៅរបស់សហគមន៍មូលដ្ឋានឱ្យកាន់តែប្រសើរឡើង ព្រមទាំងចូលរួមកាត់បន្ថយភាពក្រីក្រ តាមរយៈការលើកទឹកចិត្តឱ្យមានការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយនិរន្តរភាព។

អង្គការ WWF-កម្ពុជា បានបង្កើតការិយាល័យនៅប្រទេសកម្ពុជាក្នុងឆ្នាំ១៩៩៨ និងកំពុងធ្វើការយ៉ាងជិតស្និទ្ធជាមួយបណ្តាប្រទេសក្នុងមហាអនុតំបន់ទន្លេមេគង្គ រួមមាន ឡាវ មីយ៉ាន់ម៉ា ថៃ និងវៀតណាម ដើម្បីសម្រេចបាននូវគោលដៅអភិរក្សរបស់ខ្លួន។




© Sophearoth Ravy / WWF-Cambodia


© Lor Kimsan / WWF-Cambodia


© WWF-Cambodia

# តំបន់គោលដៅ

តំបន់អេកូឡូស៊ីសកលសំខាន់ៗទាំងបីរបស់អង្គការ WWF ផ្តោតលើការអភិរក្សនៅក្នុងប្រទេសកម្ពុជា រួមមាន តំបន់ដីគោក ទឹកសាប និងសមុទ្រ។ តាមរយៈវិធីសាស្ត្រអភិរក្សតាមតំបន់ទេសភាពដែលមានការតភ្ជាប់គ្នា អង្គការ WWF-កម្ពុជា អនុវត្តកម្មវិធីការងារនៅក្នុងតំបន់គោលដៅសំខាន់ចំនួនពីរ ដូចបង្ហាញក្នុងរូបភាពខាងក្រោម៖




## តំបន់ទេសភាពព្រៃលិចទឹកមេគង្គ (MFF)

ទន្លេមេគង្គ គឺជាប្រព័ន្ធអេកូឡូស៊ីទឹកសាបដ៏អស្ចារ្យ និងសម្បូរបែប ដែលជាជម្រករបស់ត្រី សត្វស្លាប និងថនិកសត្វជាច្រើនប្រភេទ។ តំបន់ទំនាបលិចទឹកដែលមានការប្រែប្រួលជានិច្ចនេះ មិនត្រឹមតែគាំទ្រដល់ជីវៈចម្រុះប៉ុណ្ណោះទេ ប៉ុន្តែក៏ជាខ្សែជីវិតដ៏សំខាន់សម្រាប់ការនេសាទ និងកសិកម្មរបស់ប្រជាជនកម្ពុជាផងដែរ។

- ខេត្តស្ទឹងត្រែង និងក្រចេះ
- ដែនជម្រកសត្វព្រៃសំបូរ ព្រែកប្រសព្វ និងតំបន់អភិរក្សសត្វផ្សោតទន្លេមេគង្គ










## តំបន់ទេសភាពខ្ពង់រាបភាគខាងកើត (EPL)

តំបន់ទេសភាពនេះ គ្របដណ្តប់ដោយព្រៃពាក់កណ្តាលស្រោង និងព្រៃរបោះ ដែលជាជម្រកដ៏សំខាន់សម្រាប់សត្វព្រៃកម្រ ជាពិសេសដំរីអាស៊ី ក្រពើភ្នំ ទន្សោង និងខ្លារខិន។ ជនជាតិដើមភាគតិច និងប្រជាសហគមន៍ក្នុងតំបន់ពឹងផ្អែកលើធនធានធម្មជាតិដ៏សម្បូរបែបនៃតំបន់ទេសភាពនេះដើម្បីគាំទ្រជីវភាពរស់នៅរបស់ពួកគេ។

- ខេត្តមណ្ឌលគិរី និងរតនគិរី
- ដែនជម្រកសត្វព្រៃស្រែពក និងភ្នំព្រេច



© Lor Kimsan / WWF-Cambodia

## ស្កេនទីនេះដើម្បីស្វែងយល់បន្ថែមអំពីទេសភាពរបស់យើង៖

តំបន់ទេសព្រៃលិចទឹកមេគង្គ (MFF)

តំបន់ទេសខ្ពង់រាបភាគខាងកើត (EPL)

# បញ្ហាប្រឈម និងការគំរាមកំហែងដល់តំបន់ទេសភាព

ប្រព័ន្ធអេកូឡូស៊ីនៅទូទាំងប្រទេសកម្ពុជា កំពុងប្រឈមនឹងការរិចរិលនៃទីជម្រកធម្មជាតិ និងការធ្លាក់ចុះនៃចំនួនសត្វព្រៃក្នុងអត្រាគួរឱ្យព្រួយបារម្ភ។ អង្គការ WWF-កម្ពុជា បានកំណត់កត្តាខាងក្រោមនេះ ជាការគំរាមកំហែងចម្បងដល់តំបន់ទេសភាពគោលដៅរបស់ខ្លួន៖



ការកាប់ឈើខុសច្បាប់ និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធដែលខ្វះការគ្រោងទុកត្រឹមត្រូវ



ការបរបាញ់ និងការដាក់អន្ទាក់



ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ




ការលំបាកក្នុងរបៀរការចូលរួមរបស់សហគមន៍មូលដ្ឋាន



គម្រោងវារីអគ្គិសនីនៅតាមដងទន្លេមេគង្គ

## យុទ្ធសាស្ត្រ

ការកសាងអនាគតប្រកបដោយនិរន្តរភាពសម្រាប់ប្រទេសកម្ពុជា មិនមែនមានតែការស្តារឡើងវិញនៃទីជម្រក និងចំនួនសត្វព្រៃប៉ុណ្ណោះទេ ប៉ុន្តែក៏ចាំបាច់ឱ្យមានការលើកកម្ពស់ជីវភាពរស់នៅប្រកបដោយនិរន្តរភាព ការជំរុញការប្រើប្រាស់ថាមពលកកើតឡើងវិញ និងការពង្រឹងកិច្ចសហប្រតិបត្តិការជាមួយភាគីពាក់ព័ន្ធទាំងអស់ផងដែរ។

នេះជាមូលហេតុដែលអង្គការ WWF-កម្ពុជា កំពុងអនុវត្តគម្រោង និងគំនិតផ្តួចផ្តើមជាច្រើននាពេលបច្ចុប្បន្ន ដែលផ្តោតលើគម្រោងការប្រើប្រាស់ និងផលិតកម្មប្រកបដោយនិរន្តរភាព (SCP) កម្មសិទ្ធិដីធ្លីរបស់ជនជាតិដើមភាគតិច ការអភិវឌ្ឍន៍អេកូទេសចរណ៍ ការប្រែជម្លោះទៅជាសុខដុមនីកម្មរវាងមនុស្ស និងដំរី ការប្រើប្រាស់អនុផលព្រៃឈើ និងវិស័យផ្សេងៗទៀត។

© Sothean Thou / WWF-Cambodia



ការងារនេះមិនអាចសម្រេចបានទេ បើពុំមានការគាំទ្រពីម្ចាស់ជំនួយ ដៃគូអង្គការក្រៅរដ្ឋាភិបាល និងរាជរដ្ឋាភិបាលកម្ពុជា។ យើងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ និងកោតសរសើរចំពោះការគាំទ្របន្តបន្ទាប់របស់ដៃគូទាំងអស់។

## កម្មវិធីរបស់យើង

- ការស្រាវជ្រាវ និងតាមដានជីវៈចម្រុះ
- ការពង្រឹងជីវភាពសហគមន៍
- ការគ្រប់គ្រងតំបន់ការពារ និងការអនុវត្តច្បាប់
- ភាពជាដៃគូជាមួយអង្គការសង្គមស៊ីវិល
- ការតស៊ូមតិ និងការចូលរួមលើគោលនយោបាយ
- ការផ្សព្វផ្សាយថាមពលកកើតឡើងវិញ



## គោលដៅសកលរបស់យើង

- មិនមានការបាត់បង់ជម្រកធម្មជាតិ
- មិនមានការផុតពូជនៃប្រភេទសត្វព្រៃ
- កាត់បន្ថយពាក់កណ្តាលនៃបរិមាណកាបូនដែលបញ្ចេញទៅបរិយាកាស

# ស្ថិតិ និងតួលេខរបស់អង្គការ WWF-កម្ពុជា

## ២៨ ឆ្នាំ

អង្គការ WWF-កម្ពុជា បានបំពេញការងារក្នុងមហាអនុតំបន់ទន្លេមេគង្គអស់រយៈពេល ២៨ ឆ្នាំមកហើយ។

## ១៨%

ជំរឿនឆ្នាំ ២០២៥ បានកត់ត្រាសត្វត្រយងចង្កំកសចំនួន ២៩៨ ក្បាល នៅក្នុងដែនជម្រកសត្វព្រៃសំបូរ ដែលបង្ហាញពីការកើនឡើង ១៨% បើធៀបនឹងឆ្នាំ ២០២១។



## ៨៥

ការសិក្សាដោយប្រើកាមេរ៉ាថតស្វ័យប្រវត្តិ និងជ្រូនក្នុងឆ្នាំ២០២៥ បានកត់ត្រាសត្វក្តាន់ចំនួន ៨៥ ក្បាល នៅក្នុងដែនជម្រកសត្វព្រៃព្រែកប្រសព្វ ដែលជាប្រភេទសត្វធ្លាប់ត្រូវបានគេគិតថាបានផុតពូជ មុនពេលត្រូវបានរកឃើញឡើងវិញនៅឆ្នាំ ២០០៦។

## ៥៤

យើងមានគោលបំណងគាំទ្រសហគមន៍ចំនួន ៥៤ ដើម្បីទទួលបានសិទ្ធិកាន់កាប់ដីធ្លីដោយស្របច្បាប់នៅត្រឹមឆ្នាំ ២០៣០។

WWF

Working to sustain the natural world for the benefit of people and wildlife.

together possible™ panda.org

© 2026
© 1986 Panda symbol WWF - World Wide Fund for Nature (Formerly World Wildlife Fund)
® “WWF” is a WWF Registered Trademark. WWF Avenue du Mont-Bland, 1196 Gland, Switzerland. Tel: +41 22 364 9111. Fax: +41 22 364 0332.

For contact details and further information, please visit our international website at www.panda.org